# ប្រាក់បំណាច់ពន្ធជាវគ្រួសារផ្នែក B



## Family Tax Benefit Part B—Khmer

ផ្តល់ជំនួយបន្ថែមទៅឲ្យគ្រួសារមានតែម្តាយឬឪពុក និងគ្រួសារមានឪពុកម្តាយដែលមានប្រាក់ចំណូលចំបងតែមួយ នៅពេលដែលម្តាយឬឪពុកជ្រើសយកការស្នាក់នៅឯផ្ទះ ឬធ្វើការនៅពេលខ្លះដើម្បីទទួលប្រាក់ផង និងថែទាំកូនរបស់ខ្លួនផង។

Family Tax Benefit Part B (ប្រាក់បំណាច់ពន្ធជាវគ្រួសារផ្នែកB) ត្រូវបានពិនិត្យវាយតម្លៃលើប្រាក់ចំណូលទាំងពីរគឺអ្នកទទួលប្រាក់ចំណូលច្រើនជាងគេនិងអ្នកទទួលប្រាក់ចំណូលបន្ទាប់បន្សំ។ ម្តាយឬឪពុកតែម្នាក់ដែលមានសិទ្ធិ តែងទទួលអត្រាច្រើនបំផុតនៃប្រាក់បំណាច់នេះជានិច្ច។

បើលោកអ្នករើសយកការទទួលប្រាក់បំណាច់លោកអ្នកនៅពេលពីរអាទិត្យម្តងនោះ លោកអ្នកនឹងត្រូវតែបាន់ស្មានប្រាក់ចំណូលរបស់គ្រួសារលោកអ្នកសំរាប់ឆ្នាំហិរញ្ញកិច្ចខាងមុខ។ លោកអ្នកក៏អាចរើសយកការទទួល Family Tax Benefit Part B ប្រចាំឆ្នាំជាប្រាក់ដុំសរុបផងដែរ។ **ការបើកប្រាក់ប្រចាំឆ្នាំកាត់បន្ថយលទ្ធភាពដែលលោកអ្នកទទួលប្រាក់លើសចំនួនកំណត់។**

## នរណាអាចទទួលប្រាក់បំណាច់នេះ?

លោកអ្នកត្រូវតែ៖

- ជាគ្រួសារមានតែម្តាយឬតែឪពុកនៅពេលដែលប្រាក់ចំណូលនៃម្តាយឬឪពុកបំពេញតាមការធ្វើតេស្តប្រាក់ចំណូលនៃអ្នកទទួលប្រាក់ចំណូលច្រើនជាងគេ; ឬ
- ជាគ្រួសារមានម្តាយឪពុកទាំងពីរនៅពេលដែលប្រាក់ចំណូលនៃម្តាយឪពុកទាំងពីរនាក់បំពេញតាមការធ្វើតេស្តប្រាក់ចំណូលនៃអ្នកទទួលប្រាក់ចំណូលច្រើនជាងគេ; និង
- ផ្តល់ការថែទាំឲ្យកូនក្នុងបន្ទុកចំនួន 35ភាគរយនៃពេលវេលា ឬច្រើនជាងនេះ; និង
- បំពេញតាមតម្រូវការនៃការរស់នៅក្នុងប្រទេសអូស្ត្រាលីសំរាប់គោលបំណងជំនួយគ្រួសារ។
- ប្រសិនបើលោកអ្នករួមចំណែកគ្នាក្នុងការថែទាំកូនលោកអ្នកក្នុងចន្លោះ 35 និង 65 ភាគរយនៃពេលវេលា លោកអ្នកប្រហែលជាមានសិទ្ធិទទួលមួយចំណែកម្នាក់នៃ Family Tax Benefit Part B។

បើលោកអ្នករួមចំណែកគ្នាក្នុងការថែទាំកូនលោកអ្នក លោកអ្នកអាចមានសិទ្ធិទទួល Family Tax Benefit Part B សំរាប់រយៈពេលដែលកូននោះនៅក្នុងការថែទាំរបស់លោកអ្នក។

## តើខ្ញុំអាចទទួលប្រាក់ចំនួនប៉ុន្មាន?

អត្រាទាំងអស់គឺត្រឹមត្រូវនៅថ្ងៃទី 01/07/2008

**អត្រាច្រើនបំផុតនៃ Family Tax Benefit Part B មានដូចតទៅនេះ៖**

| អាយុរបស់កូនពៅ | ពីរអាទិត្យម្តង | ប្រចាំឆ្នាំ (រួមទាំងប្រាក់ឧបត្ថម្ភ |
|---|---|---|
| ក្រោមអាយុ ៥ឆ្នាំ | $128.80 | $3,693.80 |
| 5-15ឆ្នាំ (ឬ 16-18ឆ្នាំ បើជាសិស្សរៀនពេញពេល) | $89.74 | $2,675.45 |

## តើការធ្វើតេស្តប្រាក់ចំណូលគឺជាអ្វីទៅ?

ការធ្វើតេស្តប្រាក់ចំណូលអ្នកទទួលប្រាក់ចំណូលប្រាក់ច្រើនជាងគេចំនួន $150,000 ឬតិចជាងនេះក្នុងមួយឆ្នាំ នឹងអនុវត្តចំពោះគ្រួសារមានតែម្តាយ ឬតែឪពុកនិងមានម្តាយឪពុកទាំងពីរ។ គ្រួសារមានតែម្តាយ ឬតែឪពុកតែងទទួលអត្រាច្រើនបំផុតនៃ Family Tax Benefit Part B ជានិច្ច ប្រសិនបើប្រាក់ចំណូលរបស់គេនៅក្រោមកំរិតនៃប្រាក់ចំណូលរបស់អ្នកទទួលប្រាក់ចំណូលច្រើនជាងគេ។

ក្នុងគ្រួសារមានម្តាយនិងឪពុកទាំងពីរ ការធ្វើតេស្តប្រាក់ចំណូលនៃអ្នកទទួលប្រាក់ចំណូលបន្ទាប់បន្សំនឹងអនុវត្តនៅពេលដែលប្រាក់ចំណូលនៃអ្នកទទួលប្រាក់ចំណូលច្រើនជាងគេចំនួន $150,000 ឬតិចជាងនេះក្នុងមួយឆ្នាំ។ អ្នកទទួលប្រាក់ចំណូលបន្ទាប់បន្សំអាចទទួលប្រាក់ចំនួន $4,526 ក្នុងមួយឆ្នាំ ហើយនៅតែទទួលអត្រាច្រើនបំផុតនៃ Family Tax Benefit Part B។ ប្រសិនបើប្រាក់ចំណូលរបស់អ្នកទទួលប្រាក់ចំណូលបន្ទាប់បន្សំមានចំនួនលើសពី $4,526 ក្នុងមួយឆ្នាំនោះ ប្រាក់បំណាច់ត្រូវបានកាត់បន្ថយចំនួន 20 សេនក្នុងមួយដុល្លារនៃប្រាក់ចំណូលបន្ថែម។

We speak your language ✆ 13 1202

www.familyassist.gov.au

Australian Government
Family Assistance Office

មាតាបិតាទាំងឡាយដែលមានសិទ្ធិ នឹងទទួល Family Tax Benefit Part B ខ្លះ ប្រសិនបើប្រាក់ចំណូលរបស់អ្នកមានប្រាក់ចំណូលទាបមានចំនួនតិចជាង៖

- $22,995 ក្នុងមួយឆ្នាំ ប្រសិនបើកូនពៅមានអាយុក្រោម 5 ឆ្នាំ ឬ
- $17,904 ក្នុងមួយឆ្នាំ ប្រសិនបើកូនពៅមានអាយុចន្លោះពី 5 និង 18 ឆ្នាំ

## តើ Family Tax Benefit Part B Supplement (ប្រាក់ឧបត្ថម្ភបំណាច់ពន្ធដារគ្រួសារផ្នែក B) គឺជាអ្វី?

នេះគឺជាកំណើននៃអត្រាប្រចាំឆ្នាំនៃ Family Tax Benefit Part B ចំនួនដល់ទៅ $335.80 សំរាប់គ្រួសារនីមួយៗ។ ប្រាក់នេះត្រូវបានបង់ឲ្យនៅក្រោយ ដំណាច់ឆ្នាំហិរញ្ញកិច្ច នៅពេលដែលលោកអ្នកនិងដៃគូលោកអ្នកដាក់របាយការណ៍បង់ពន្ធដារប្រចាំឆ្នាំរបស់លោកអ្នក។ សូមទាក់ទង Family Assistance Office (ការិយាល័យផ្តល់ប្រាក់ជំនួយដល់គ្រួសារ) ប្រសិនបើលោកអ្នកនិងដៃគូលោកអ្នកមិនត្រូវការដាក់របាយការណ៍បង់ពន្ធដារប្រចាំឆ្នាំទេនោះ។ Family Tax Benefit Part B Supplement (ប្រាក់ឧបត្ថម្ភបំណាច់ពន្ធដារគ្រួសារផ្នែកB) ត្រូវប្រើដើម្បីសងទូទាត់ការជំពាក់ប្រាក់បំណាច់បើកលើសចំនួនកំណត់ដោយសារតែគ្រួសារត្រូវបានទទួលប្រាក់លើសចំនួនកំណត់។

## ឪពុកម្តាយដែលវិលទៅធ្វើការវិញ

ចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2005 តទៅ ឪពុកម្តាយដែលវិលទៅធ្វើការវិញក្រោយពីប្រសូតកូនហើយនោះ អាចមានសិទ្ធិទទួល Family Tax Benefit Part B សំរាប់អំឡុងពេលនៃឆ្នាំហិរញ្ញកិច្ចនៅមុនពេលវិលទៅធ្វើការវិញ។ បើលោកអ្នក ឬគូកំណាន់លោកអ្នកបានវិលទៅធ្វើការវិញក្រោយពីប្រសូតកូនហើយនោះ លោកអ្នកគួរប្រាប់ Family Assistance Office។

## ដើម្បីទទួលព័ត៌មានបន្ថែម៖

- ទូរស័ព្ទទៅកាន់ Family Assistance Office តាមលេខ **13 1202** រវាងម៉ោង 8:00ព្រឹក និង 5.00ល្ងាច (EST) ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ ដើម្បីទទួលពត៌មានជាភាសាក្រៅពីអង់គ្លេស។
- បើកមើលវិបសៃ **www.familyassist.gov.au**
- អញ្ជើញទៅកាន់ Family Assistance Office (ការិយាល័យផ្តល់ប្រាក់ជំនួយដល់គ្រួសារ)លោកអ្នកនៅជិតជាងគេដែលស្ថិតក្នុងការិយាល័យ Medicare Australia, Centrelink Customer Service Centres ហើយនិងកន្លែងទទួលភ្ញៀវនៃការិយាល័យពន្ធដារអូស្រ្តាលី។